# សៀវភៅគតិលោក
## ភាគ ទី១០



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

ChanBoKeo.com

# មតិអ្នករៀបរាង

ខ្ញុំព្រះករុណាខ្ញុំបាទដែលបានចំណាយពេលវេលាដែលមានបន្តិចបន្តួចក្នុងការវាយនៅសៀវភៅគតិលោកនេះ ដើម្បីងាយស្រួលក្នុងអានបានគ្រប់ៗគ្នា ព្រោះគិតថាសៀវភៅគតិលោកនេះមានអត្ថរស អត្ថប្រយោជន៍សំរាប់ជនគ្រប់រូបបានជាប្រយោជន៍ក្នុងការរស់នៅប្រចាំថ្ងៃ។

ហេតុដែលខ្ញុំព្រះករុណាខ្ញុំបាទវាយអត្ថបទគតិលោកនេះទាំងពីភាគទី១រហូតដល់ភាគទី១០ ហើយបានចប់សព្វគ្រប់នោះដោយសារសៀវភៅនេះពិបាកអាននិងមានអក្សរខ្លះរលប់បាត់តែម្តងធ្វើឲ្យពិបាកក្នុងការអានទៀតផង ហើយខ្ញុំបានជាប់និងរសរបស់សៀវភៅនេះទៀតម្ល៉ោះហើយបានជាមានសទ្ធាមាំព្យាយាមរហូតបានសម្រេចដូចបំនង។

ជាទីបញ្ចប់នេះខ្ញុំព្រះករុណាខ្ញុំបាទសូមជូនបុណ្យកុសលទៅដល់មាតាបិតា និងឧទ្ទិសបុណ្យកុសលដល់ ( ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ) ដែលលោកបានរៀបរាងសៀវភៅទុកជាប្រយោជន៍ដល់កូនខ្មែរគ្រប់គ្នាបានសិក្សារៀនសូត្រ។

សូមបងប្អូនអនុមោទនាផលបុណ្យពីខ្ញុំបាទផង

ថៃ ប៊ុនឆាយ

ភ្នំពេញ ថ្ងៃ សុក្រទី ៥ ខែតុលា ព. ស ២៥៥៦ ។

ដំណើរសុរិយារះឡើងបន្តិចម្តងៗ រហូតដល់អស្តង្គតយ៉ាងណា ការងារទាំងឡាយដែលយើងធ្វើដោយមិនឈប់ឈរនោះនិងដល់ទីបញ្ចប់ក៏យ៉ាងនោះដែរ។

# រឿងសត្វភេពីរចែកផ្លូវគ្នារកអាហារ

មានសត្វភេពីរ ភេមួយដើររកត្រីខាងទឹកជ្រៅភេមួយទៀតដើររកត្រីខាងទឹករាក់ៗ ថ្ងៃមួយ ភេទាំងពីរចុះស្ទុងមុជទឹកដេញចាប់ត្រីបានត្រីរ៉ស់មួយ ទើបនាំគ្នាទាញឡើងគោក ដើម្បីនឹងចែកគ្នាៗ ភេខាងទឹកជ្រៅពោលថា "យើងមុជដើរខាងទីជំរៅបានក្ដីលំបាកច្រើន ដូច្នេះយើងត្រូវបានចំណែកខាងក្បាល"ៗ ឯភេខាងទឹករាក់ក៏ឆ្លើយថា "ត្រីនេះកុំតែបានយើងស្ទាក់នៅទឹករាក់កុំអីវារួចខ្លួនទៅទីឯណាៗបាត់ហើយដែលបានត្រីនេះ ក៏ព្រោះកំលាំងយើងៗស្ទាក់ចាប់បាន ដូច្នេះចំណែកខាងក្បាលនោះ ត្រូវបានយើងទើបគួរ"ៗ

ឯភេទឹកជ្រៅពុំព្រមចែក ទើបភេទាំងពីរកើតឈ្លោះគ្នា នាំគ្នាទៅរកចចកជាចៅក្រមឲ្យចែកឲ្យ ឯចចកនោះជាសត្វលោភកាលបើភេទាំងពីរមកប្ដឹងឲ្យចែកត្រីដូច្នោះ ក៏សួរទៅថា "ភេណាដើរទឹកជ្រៅ ភេណាដើរទឹករាក់?" ភេទាំងពីរក៏ថ្លែងសេចក្ដីប្រាប់តាមទីដំណែងខ្លួនទីទៃៗ ទើបចចកកាត់ត្រីនោះជាបីភាគភាគក្បាលឲ្យទៅភេដែលទឹកជ្រៅ ភាគកន្ទុយឲ្យទៅភេដែលដើរខាងទឹករាក់ភាគកណ្ដាលចចកយកបរិភោគខ្លួនឯង ហើយថាយើងចែកនេះជាយុត្តិធម៌ល្អហើយ បើរូបណាពុំសុខចិត្ត ឲ្យទៅប្ដឹងសាលាណាទៀតចុះៗ ឯភេ



ទាំងពីរ កាលណាបើឃើញចចកវាយយកភាគកណ្ដាលអស់ដូច្នោះ ក៏តូចចិត្តនឹកស្ដាយចំណីរបស់ខ្លួនពន់ពេកណាស់ តែភេទឹករាក់ដែលបានកន្ទុយត្រីនោះ ពុំសុខចិត្តខ្លាំង គិតថាកន្ទុយត្រីនេះមានសាច់ក៏តិច សាច់សោតក៏ឥតជាតិ ស៊ូខាងក្បាលពុំបាន សាច់ក្បាលវិសេសជាង ឥឡូវចចកកាត់ក្ដីឲ្យទៅខាងភេទឹកជ្រៅហើយ អញនេះ ឃើញថាចាញ់ប្រៀបគេខ្លាំងណាស់ បើដូច្នេះ មានតែតវ៉ានឹងភេទឹកជ្រៅថា "អ្នកឯងស្វែងមុជខាងទឹកជ្រៅ ក៏បានព្រោះយើងខាងទឹករាក់នៅស្ទាក់ទើបចាប់ត្រីនេះបាន មួយសោតក្ដីនឿយក្ដីលំបាកនោះ នឹងលើសគ្នាក៏ទេ នឿយដូចៗគ្នា អើហេតុអ្វីអ្នកឯងក៏បានសាច់ខាងក្បាល មានទម្ងន់ជាងសាច់កន្ទុយយ៉ាងនេះ សាច់ក្បាលនោះ គួរបានមកយើងខ្លះទើបត្រូវ បើអ្នកឯងមិនបែងឲ្យយើងទេ យើងនឹងប្ដឹងតទៅសាលាឯទៀត ឲ្យលោកចែកតាមច្បាប់ម្ដងទៀត"ៗ ឯភេទឹកជ្រៅក៏ឆ្លើយថា "បើអ្នកឯងមិនសុខចិត្ត ចង់ទៅប្ដឹងឯណាទៀតក៏ទៅចុះ ស៊ូឲ្យអស់ក្បាលអស់កន្ទុយខានស៊ីទាំងអស់គ្នាទៅចុះ"ៗ

ឯភេទឹករាក់ ក៏ទៅកាន់សំណាក់នៃខ្លាត្រី ដល់ហើយក៏ចូលទៅប្ដឹងតាមរឿងដែលភេទឹកជ្រៅ មិនចែកបែងភាគក្បាលត្រីឲ្យនោះសព្វប្រការៗ

ឯខ្លាត្រីបានឮដូច្នោះ ក៏តបថា "អើចចកកាត់ចែកឲ្យយ៉ាងនោះ មិនត្រូវតាមច្បាប់ក្នុងមាត្រាចូលហ៊ុនគ្នាទេ ច្បាប់ចូលហ៊ុននោះត្រូវតែចែកឲ្យស្មើភាគគ្នានឹងកាត់យល់ដោយផ្លូវជ្រៅ ផ្លូវរាក់នោះឯណាក៏បានព្រោះក្ដីនឿយ ក្ដីលំបាកចុះកម្លាំងដូចគ្នា រឿងនេះត្រូវថ្លឹងដោយប្រាជ្ញទើបគួរទើបសមគ្នា នឹងផ្លូវយុត្តិធម៌បាន" ថាហើយខ្លាត្រី ក៏លើកយកត្រាជូមកតាំងហើយយកក្បាលត្រី ដាក់លើអ៊ុយម្ខាង យកកន្ទុយត្រីដាក់លើអ៊ុយម្ខាង តាំងថ្លឹងមើលដោយទម្ងន់ប៉ុង។

ឯក្បាលត្រីដោយមានឆ្អឹងធំក៏ធ្ងន់ចុះ ខ្លាត្រីក៏ថា "អះអា ខាងនេះមានទម្ងន់ជាង ត្រូវយកសាច់ចេញខ្លះទើបបាន" ថាហើយ ក៏លូកយកក្បាលត្រីចេញចាក់អ៊ុយ ហើយឱនខាំស៊ីត្រង់សាច់អមក ហើយដាក់ទៅថ្លឹងទៀត ថ្លឹងទៅខាងក្បាលស្រាលបះឡើងខាងកន្ទុយក៏ធ្ងន់ចុះ។ ខ្លាត្រីក៏ថា "អះតា ខាងនេះបាស់ជាងត្រូវយកសាច់ចេញខ្លះ"។ ថាហើយក៏លូកយកកន្ទុយចេញចាកអ៊ុយ ហើយឱនខាំស៊ីសាច់ខាងគល់កន្ទុយនោះ ហើយដាក់ថ្លឹងទៀតថ្លឹងទៅខាងកន្ទុយស្រាលបះឡើងខ្លាត្រីក៏លូកយកក្បាលមកខាំស៊ីហើយដាក់ថ្លឹងទៅទៀត។ ខ្លាត្រីថ្លឹងត្រីក្លែងមិនឲ្យស្មើ ចេះតែស៊ីទៅស៊ីមក ទាល់តែអស់សាច់នៅតែឆ្អឹងទាំងសងខាង ទើបថ្លឹងឯក្រោយឲ្យស្មើបានហើយក៏ដាក់ចុះចាកត្រាជូ ហៅភេទាំងពីរថា "ចៅឯងទាំងពីរចូរមើលចុះយើងថ្លឹងចែកនេះត្រូវដោយយុត្តិធម៌ល្អហើយ តាមចិត្តចៅណាយកភាគខាងណាក៏មកយកចុះ ភាគទាំងពីរនេះមិនលើសមិនខ្លះទេ"។ ឯភេទាំងពីរបានឃើញកិរិយាខ្លាត្រីក្លែងថ្លឹងស៊ីសាច់អស់ខាងក្បាលនៅតែរលា ខាងកន្ទុយនៅតែចុងជាយ នឹងយកទៅអាស្រ័យពុំបានដូច្នោះ ក៏កើតខឹងចិត្តស្ដាយគំនិត ប្រព្រឹត្តខុស លុះទៅដោយក្ដីលោភចង់បានតែឯង មិនបែងបទអធ្យាស្រ័យ ក្ដីសាមគ្គីនឹងគ្នាកើតខឹងប្ដឹងផ្ដល់ទាល់តែអស់ស្បៀងទៀងខ្លួន ភេទាំងពីរកើតវិប្បដិសារី រំឭកក្ដីខ្លួនធ្វើខុសកើតក្ដីក្ដៅក្រហាយ ហើយក៏បោលចំណែកខ្លួនទៅកាន់លំនៅនៃអាត្មាទីទៃៗហោង។ រឿងនេះ អញ្ជើញប្រាជ្ញមានបញ្ញាពិចារណាទៅចុះ។



ភេអើយភេពីរ ខេះខឹងមមីរ បែកក្ដីសាមគ្គា ព្រោះលោភលាភឯង មិនបែងចែកគ្នា ទៅប្ដឹងដល់វា ចចកឲ្យចែក។ ធម្មជាតិចចកជាសត្វនៃនក(១) វាយកចំណែក កណ្ដាលសាច់ច្រើន ចំរើនអ្នកចែក ចុងដើមបំបែក បានភេទ្វេហា។ ក្រោយភេបោទខឹង ពាំត្រីទៀតណា ខ្លាតាំងត្រាជូ ថ្លឹងផ្គុំភ្នែកត្រា ទំនាំស្មើគ្នា នៅសល់តែឆ្អឹង។

**ចប់ តំរាចៅក្រមកោង ជាគតិទី ៦៥។**

---

**(១) គួរថា "លៃលក"**

# រឿងបុរសម្នាក់ស្លាប់ទៅកើតជាហង្សមាស

មានព្រាហ្មណ៍ម្នាក់ នៅក្នុងនគរពារាណសីព្រាហ្មណ៍នោះលុះធ្វើកាលកិរិយាស្លាប់ទៅៗ កើតជាសុវណ្ណហង្សមួយ នៅក្នុងព្រៃហិមពាន្ត ហង្សមាសនោះរឮកជាតិកំណើតខ្លួនបានដឹងថា នាងព្រាហ្មណីជាប្រពន្ធខ្លួន នឹងនាងធីតាទាំងឡាយ ជាកូនខ្លួនដល់នូវក្តីក្រីក្រតោកយ៉ាកលំបាកទុគ៌ត រកស៊ីដោយការបំរើស៊ីឈ្នួលគេដូច្នោះ ក៏កើតចិត្តអាណិតដល់ប្រពន្ធក្រៃពេក ទើបហើរមកកាន់ផ្ទះកូនប្រពន្ធនោះហើយនិយាយប្រាប់រឿងខ្លួនជាស្វាមីជាបិតាស្លាប់ទៅកើតជាសុវណ្ណហង្សមកនេះដើម្បីនឹងជំរុះស្លាបមាស ១-២ ឲ្យកូនប្រពន្ធយកទៅលក់ចិញ្ចឹមជីវិតកុំឲ្យកូនប្រពន្ធធន់ទៅធ្វើការស៊ីឈ្នួលគេឡើយ ហង្សប្រាប់សេចក្តីសព្វប្រការហើយ ក៏ជំរុះស្លាបមាស១ ឲ្យទៅនាងធីតាហើយផ្តាំថា បើកូនប្រពន្ធលក់ស្លាបមាស១ នេះចាយអស់ក្នុងកាលណាសឹមយើងមកជំរុះឲ្យក្នុងកាលនោះទៀត ផ្តាំហើយហង្សមាសក៏លាកូនប្រពន្ធហើរវិលទៅកាន់លំនៅនៃអាត្មា ឰដ៏ព្រៃព្រះហិមពាន្តវិញហោង។

ឯនាងព្រាហ្មណីនឹងធីតាទាំងឡាយ ចាប់ដើមពីបានស្លាបហង្សមាសលក់ចំណាយចាយចិញ្ចឹមជីវិតមក ក៏លែងទៅធ្វើការស៊ីឈ្នួលអ្នកឯណា



ឱស្សាហ៍សន្សំទ្រព្យធនបានឡើងជាអ្នកមានគ្រាន់បើ ឯសុវណ្ណហង្សនោះ តែងមកជំរុះស្លាបឲ្យគ្រប់ៗកាល លុះចំណេរតមក នាងព្រាហ្មណីកើតលោភចេតនាប្រាថ្នាចង់បានចង់មានឆាប់ ទើបនិយាយនឹងធីតាអាត្មាថា "កូនអើយ! យើងមានប្រាក់ចាយបាយស៊ី សព្វថ្ងៃនេះក៏ព្រោះហង្សជាបិតានាងឯង មកជំរុះស្លាបមាសឲ្យយើងក្នុងកាលម្តងៗ ប្រសិនបើហង្សមិនមក យើងនឹងបានអ្វីចាយទិញដូរវត្ថុអាស្រ័យតទៅ ហេតុនេះម្តាយយល់ថា បើហង្សនោះមកក្នុងថ្ងៃណា យើងនឹងនាំគ្នាចាប់ដកយកស្លាបយករោមឲ្យអស់រលីង ទុកជាទុនបានច្រើនទៅមុខតែម្តង កុំឲ្យមានក្តីភិតភ័យនឹងក្តីក្រតទៅទៀត"។

ឯនាងធីតាទាំងឡាយ ឮម្តាយបបួលដូច្នោះក៏ហាមម្តាយថា "ការដែលម៉ែឯងគិតនេះ មិនត្រូវទេយើងជាកូនមិនព្រមធ្វើតាមឡើយ"។ ថ្ងៃមួយសុវណ្ណហង្សមកកាន់ផ្ទះ ដើម្បីនឹងជំរុះស្លាបឲ្យឯនាងព្រាហ្មណីក៏ស្រដីលួងលោមសំណេះសំណាលនឹងហង្សនោះដោយមាយា បានជិតហង្សកាលណាក៏ចាប់ហង្សនោះជាប់ហើយសង្កត់ដកយករោមស្លាបកន្ទុយ ហង្សនោះទាល់តែអស់ឥតសល់ ហង្សនោះបានក្តីទុក្ខវេទនាដោយគេដកស្លាបពន់ពេកណាស់ ខំបម្រះលូនចូលទៅក្នុងទីមានរបាំងបាំងខ្លួនទៅបាន ឯរោមស្លាបទាំងឡាយ ក៏ក្លាយជាពណ៌សដូច

ស្លាប់កុកទាំងអស់មេព្រាហ្មណីយកទៅលក់ឲ្យគេ ក៏ពុំមាននរណាត្រូវការទិញយកឡើយ ។

ឯហង្សនោះទ្រាំទុក្ខវេទនានៅត្រាតែរោមថ្មីដុះឡើងហើយបានក៏ហើរទៅកាន់ព្រហិមពាន្ត ពុំបានមកកាន់ផ្ទះនាងព្រាហ្មណីនោះទៀតឡើយ ចាប់ដើមពីថ្ងៃនោះមក នាងព្រាហ្មណីនោះខាតលាភគឺពុំមានអ្វីលក់ដូរចែកចាយដូចកាលថ្ងៃមុនៗ នោះទៀតឡើយក៏ធ្លាក់ខ្លួនជាស្រីទុរគតវិញហោង ។

រឿងនេះ បានគតិដល់បុគ្គលមានក្តីមហិច្ឆតាប្រាថ្នាបានច្រើនតែម្តង ក្តីលោភនោះនាំឲ្យខាតលាភវិញ ព្រោះអំពើហួសប្រមាណក្នុងកាលលាភនឹងឲ្យដូចអ្នកបេះផ្លែឈើដំណាំ គឺកាប់មែករលើងឫសគល់អស់តែម្តង បុគ្គលប្រថ្នាលាភ លើសកាលកំណត់មិនសន្សឹមៗទៅតាមកាល លោភចង់បានឲ្យច្រើនតែម្តង លាភនោះនឹងខាតនៅត្រឹមនោះ ពុំបានឲ្យផលតទៅទៀត ដូចនាងព្រាហ្មណីលោភដករោមហង្សរបស់លាភវិញនោះឯង ។

## រឿងបុរសចិញ្ចឹមមេមាន់

មួយទៀត និទានចៅបុរសម្នាក់ចិញ្ចឹមមេមាន់ដើម្បីយកពងលក់ មេមាន់នោះលុះដល់កំណត់ពង ក៏ពងក្នុង១ ថ្ងៃមួយៗ រៀងទៅតាម



ធម្មតាឯចៅម្ចាស់មាន់លោភចង់បានច្រើនតែម្តង ក៏ចាប់មេមាន់នោះមកវិតយកពងឲ្យអស់តែម្តង ឯពងខ្ចីពងចាស់ទាំងឡាយក៏បែកល្អិតខ្ទេចខ្ទី ដោយដៃចៅនោះវិតច្របាច់យ៉ាងខ្លាំង ទាំងមេមាន់សោតធន់នៅពុំបានក៏ស្លាប់វិនាសបង់ក្នុងកាលនោះឯង ចៅម្ចាស់មាន់ ក៏បង់លាភនៅត្រឹមនោះឯង ។ បុគ្គលបន្ទាន់ចង់មានឆាប់មិនធ្វើតាមសណ្តាប់សន្សឹមៗ ទៅបំបោលតែម្តងការនោះមិនស្ថាពរថិតថេរចេរកាលឡើយ សឹងធ្លាក់នៅក្នុងកាលវិនាសវិញហោង ។ មួយទៀត បុគ្គលរៀនសូត្រវិជ្ជាអ្វីៗ ហើយបន្ទាន់ចង់ឆាប់ក្តីបុគ្គលស្វែងទ្រព្យបន្ទាន់ចង់ឆាប់ក្តី បុគ្គលឡើងភ្នំ បន្ទាន់ចង់ឆាប់ បុគ្គលសេពកាមគុណ បន្ទាន់ចង់ឆាប់ក្តី បុគ្គលខឹងរហ័សក្តី បុគ្គលទាំង៥ពួកនេះ សឹងបាត់ធ្លាក់នៅកណ្តាលផ្លូវ ទៅមិនដល់ត្រើយឡើយ ។

បទហាមការបន្ទាន់ ការរហ័សនេះមានក្នុងបទបាលីក្នុងលោកនីតិថា ដូច្នេះ ៖

សិនេ សិប្បំ សិនេ ធនំ
សិនេ បព្វតមារុយ្ហ
សិនេ កាមស្ស កោធស្ស
សិនេ បញ្ចិតុណោ ឥមេ

ប្រែថា រៀនសិល្បកុំរានបន្ទាន់ញាប់ស្វែងទ្រព្យសន្សំកុំខំខ្លាំង

ឡើងភ្នំសន្សឹមកុំប្រណាំង សេពកាមកំលាំងតិចៗខឹងឃោរតិចៗ កុំឲ្យស៊ីនកាមគុណទាំង៥ មាត្រា សន្សឹមតិចៗមើលកិរិយាលោកថា សន្សឹមកុំបំបោល ។

(បទ) ហង្សអើយហេមហង្ស ហើរទៅស្រោចស្រង់ ភរិយាធីតា ជិនុះស្លាបឲ្យដោយក្តីមេត្តា មិនគិតកលខ្វា ភរិយាលោភធំ ។ លោភលន់លើសកាល មិនដើរកណ្តាល សន្សឹមសន្សំ ដកអស់តែម្តង គរវាងទាំងគុម្ព រំលើងរំល រំលាយលាភលាញ ។

**ចប់តម្រាប្រាថ្នារួសរាន់បន្ទាន់ខ្លាំង ជាគតិទី ៦៦។**

## រឿងចចកចេះមន្តម្យ៉ាងហៅបថវីជយ
## លើកពលសត្វទៅដណ្តើមយកនគរពារាណសី

មានព្រាហ្មណ៍ម្នាក់ចេះមន្តវិជ្ជាវិសេសហៅថាបថវីជយមន្ត ថ្ងៃមួយព្រាហ្មណ៍នោះចូលទៅក្នុងព្រៃភ្នំ ហើយទៅអង្គុយលើខ្នងសិលាថ្មដាមួយ តាំងស្វាធ្យាយរាយសូត្រនូវបថវីជយមន្តនោះ លុះចប់ហើយក៏វិលទៅកាន់គេហដ្ឋាននៃអាត្មាវិញ ក្រោយនោះមិញ មានសត្វចចកមួយដេកនៅក្នុងរូងថ្ម បានឮបថវីជយមន្តដែលព្រាហ្មណ៍សូត្រស្វាធ្យាយនោះ ក៏ចាំចេះស្ទាត់បានព្រោះស្ទាត់ចំណាន អំពីជាតិមុនមកធ្លាប់កើតជាព្រាហ្មណ៍ចេះមន្តនោះឯង ។



ចចកនោះកាលណាចេះចាំមន្តនោះហើយក៏តាំងស្វាធ្យាយរាយមន្តនោះឡើយ មន្តនោះមានអំណាចអាចហានក្លៀវក្លា បណ្តាពួកសត្វចតុប្បាទទាំងឡាយមានរាជសីហ៍សិង្ហតោ គោ សេះ ដំរី ក្របី ខ្លា ប្រើស ក្តាន់ជាដើម សឹងខ្លបខ្លាចអំណាចមន្តនោះមហិមានាំគ្នាមិតមូលចូលមកចោមរោមដោយសបរិវារ ឯចចកនោះក៏កើតមានះ ស្រវឹងយសលើកកំពស់តាំងខ្លួនជាស្តេចសម្រេចការ ហៅថាព្រះបាទសព្វទាឋរាជ មានអំណាចលើសសត្វចតុប្បាទក្នុងលោកិយ ហើយតាំងមេចចកមួយជាអគមហេសី ថ្វាយនាមជាព្រះសិង្គាលីទេវីជាគាប់ហឫទ័យនៃស្តេចសព្វទាឋរាជនោះឯង ។

លុះនៅយូរបន្តិចមក ចចកនោះកើតលោភចេតនាប្រាថ្នាចង់បានសម្បត្តិក្នុងនគរពារាណសី ដើម្បីនឹងកំចាត់ពួកមនុស្សទាំងអស់នោះឲ្យរត់ចេញចាកស្រុកហើយអាត្មាឯងនឹងយកនគរនោះ តាំងសោយរាជ្យចចកនោះគិតដូច្នេះហើយ ក៏ហៅពួកសត្វចតុប្បាទទាំងឡាយមកជាមួយពលសកលយោធា ហើយឲ្យដំរីពីរដើរទន្ទឹមដូចជាទឹមនឹមមួយ ឲ្យកេសររាជសីហ៍ឡើងឈរជាន់ខ្នងដំរីទាំងគូរនោះ អាត្មាឯងក៏នាំនាងសិង្គាលីទេពី ជិះលើខ្នងនៃកេសររាជសីហ៍នោះ ហើយឲ្យពួកពលដើរជាក្បួនព្យុហ៍ទ័ព លើកទៅចោមរោមព័ទ្ធនគរ...

ពារាណសី ។ ឯពួកសត្វទាំងឡាយ ប្រដាយគ្នាដើរជាក្បួនព័ទ្ធនគរពារាណសីដេរដាសពាសពេញ មានចម្ងាយចេញទៅ១២យោជន៍ដោយជុំវិញ ទើបស្តេចសព្វទាឋរាជឲ្យនាំសារ ចូលទៅទូលស្តេចពារាណសីថា "យើងទ្រង់នាមសព្វទាឋរាជ ជាចមពលលើពួកសត្វចតុប្បាទទាំងឡាយ លើកពលសត្វមកនេះដើម្បីនឹងយកក្រុងពារាណសីនេះជារបស់យើង ថាបើស្តេចពារាណសី នឹងចង់តតាំងប្រណាំងប្រឡងឫទ្ធិនឹងយើងក៏ឲ្យរៀបក្បួនទ័ព លើកចេញមកច្បាំងក្នុងកាលឥឡូវនេះ ឬមួយមានចិត្តខ្លបខ្លាចអំណាចយើង មិនហ៊ានប្រឡងតេជដែទេក៏ឲ្យស្តេចពារាណសីបើកទ្វារនគរចាំទទួលយើងៗនឹងចូលទៅក្នុងកាលឥឡូវនេះឯង" ។

ឯបណ្ដាលមហាជនទាំងឡាយ មានស្តេចជាដើមកាលបើឃើញពួកសត្វចតុប្បាទទាំងឡាយ លើកមកចោមព្រះនគរមានសភាពដូច្នោះ ក៏សឹងភិតភ័យតក់ស្លុត នាំគ្នារត់ឡើងផ្ទះឡើងប្រាសាទ បិទទ្វាររបងទ្វារកំពែងទ្វារផ្ទះទីទៃៗ ។

ឯស្តេចពារាណសី ក៏ឲ្យប្រជុំនាម៉ឺនមុខមន្ត្រីពិភាក្សាការតតាំងនឹងទ័ពស្តេចចចកនោះ កាលណោះមានបុរោហិតម្នាក់ជាអ្នកមានសតិបញ្ញាក្រាបទូលថា "ធម្មតាកងទ័ពសត្វតិរច្ឆាននេះ វានឹងមានគ្រឿង



សស្ត្រាវុធអ្វី ក្រៅអំពីស្នែងចង្កូមធ្មេញក្រញ៉ាំជើងវានោះក៏ទេ ឬអាងឫទ្ធានុភាពទេវទ្យាគមវិជ្ជាម្យ៉ាងៗទេដឹង? បើដូច្នេះចាំទៅនិយាយមើលកលការវាសិន ជាវាមានឫទ្ធិយ៉ាងណា បានជាវាក្លាហានហ៊ានមកធ្វើសឹកនឹងយើងជាមនុស្សនេះ" ទូលហើយរាជបុរោហិតនោះឡើងទៅលើប៉មកំពែងជាស្ថានខ្ពស់ ហើយស្រែកសួរថា "ហៃស្តេចសព្វទាឋរាជ, អ្នកមានអំណាចគង់លើខ្នងកេសររាជសីហ៍ មានដំរីជាពាហនៈរងខាងក្រោម ជាចមពលលើពួកសត្វចតុប្បាទ លើកព្យូហៈមកមានទំហំ ១២ យោជន៍ដើម្បីមកច្បាំងនឹងយើងជាជាតិមនុស្សនេះ តើអ្នកមានគ្រឿងសាស្ត្រាវុធអ្វីខ្លះអាចយកជ័យជំនះយើងជាជាតិមនុស្សនេះបានហៈ? ។

ឯស្តេចសព្វទាឋរាជ ក៏ឆ្លើយតបទៅថា "យើងមិនចាំបាច់មានអាវុធអ្វីនាំឲ្យពិបាក នឹងចាក់នឹងកាប់នោះទេយើងមានតែអាវុធវិសេសមួយយ៉ាង គឺកេសររាជសីហ៍ ជាព្រះទីនាំងយើងនេះ យើងនឹងប្រើឲ្យស្រែកជាសម្រែកសីហនាទកាលណា បណ្ដាលមនុស្សទាំងឡាយក្នុងព្រះនគរនេះ ក៏នឹងវិនាសស្លាប់ទាំងអស់ជាម្ដង នគរនេះហោងក៏នឹងធ្លាក់នៅក្នុងកណ្ដាប់ដៃនៃយើងនេះឯង ។

ឯបុរោហិតបានឮដូច្នោះ ក៏ចូលចិត្តបាន ទើបនិយាយអង្វរទៅថា

"ឱមហារាជ ការនេះយើងស្តាប់បានហើយ តែចាំយើងចូលទៅទូល ព្រះបាទ អ្នកជាម្ចាស់យើងឲ្យទ្រង់ជ្រាបសិន ជាស្តេចនឹងព្រមលើក រាជសម្បត្តិថ្វាយដល់មហារាជ ឬនឹងគិតប្រឹក្សាយ៉ាងម៉េចទៅទៀត ថាហើយរាជបុរោហិតនោះ ចុះចាកប៉មម្នីម្នាចូលទៅទូលស្តេចពារា ណសី តាមសេចក្តីនោះហោង ៗ

ឯស្តេចពារាណសីបានជ្រាបហេតុដូច្នោះ ក៏ភិតភ័យស្លុតព្រះហឫ ទ័យ ទើបទ្រង់ប្រឹក្សាការនោះនឹងបុរោហិតទៀត បុរោហិតក៏ទទួល អាសា ទើបចាត់អមាត្យឲ្យយកស្គរចរទៅវាយ ប្រាមប្រាប់អស់អ្នក នគរ ឲ្យយកសំឡីគរឬសំពត់ចុកត្រចៀកទាំងអស់គ្នាដោយហោច ទៅតែសត្វចិញ្ចឹមមានឆ្កែឆ្មាជាដើម ក៏ឲ្យចុកត្រចៀកទាំងអស់ ៗ

បុរោហិតនោះ ចាត់ការរក្សាជីវិតអ្នកនគរស្រេចហើយ ក៏ឡើង ទៅលើប៉មទៀត ហើយនិយាយចំអកឡកឲ្យស្តេចចចកនោះថា ហៃ ចៅមពលសត្វចតុប្បាទអើយ អ្នកឯងអួតថានឹងឲ្យកេសររាជសីហ៍ ស្រែក ដើម្បីនឹងឲ្យវិនាសដល់ពួកមនុស្សនោះយើងយល់ថារាជសីហ៍ គង់មិនស្តាប់ពាក្យអ្នកឯងជាប្រាកដ ៗ ឯស្តេចចចកលុះឮពាក្យបុរោ ហិតថាដូច្នោះក៏កើតមានះឡើងខ្លាំង តាំងទទោកជើងឲ្យសញ្ញាដល់ កេសររាជសីហ៍ៗក៏ទទួលបង្គាប់ មុននឹងស្រែកនោះរាជសីហ៍ ក៏តាំង



ផាន់ជ្រែងជើងទាំងបួនខ្ទាប់លើខ្នងដំរីទាំងពីរ ហើយស្រែកដោយ សម្រែកយ៉ាងខ្លាំងឡើងសម្លេងនោះ ក៏លាន់ខ្ទប់ទៅលើត្រចៀក នៃសត្វទាំងឡាយៗ មានដំរីជាដើមក៏បែកត្រចៀកដួលចុះស្លាប់ វិនាសពាសពេញលើធរណី ឯដំរីព្រះទីនាំងទាំងពីរក៏ដួលទ្រោមចុះ រាជសីហ៍នោះក៏ធ្លាក់ទៅដល់ផែនដីឯស្តេចសព្វទាឋរាជ នឹងសិង្គាលីជា មហេសី ក៏ធ្លាក់ទៅក្រោមពោះដំរីៗ ដួលសង្កត់ស្លាប់ទាំងពីរប្រាណ នៅក្នុងស្ថាននោះឯង ៗ

សត្វទាំងឡាយ សឹងវិនាសទាំងអស់នៅសល់តែកេសររាជសីហ៍ មួយរាជសីហ៍នោះឃើញពួកខ្លួនស្លាប់អស់ហើយ ក៏ភិតភ័យទើបបោ លបោះផ្លោះទៅកាន់ព្រៃព្រះហិមពាន្តវិញហោង ៗ

ឯបុរោហិតនោះ លុះបានឃើញទ័ពសត្វដល់នូវក្តីវិនាសដួលស្លាប់ ពាសពេញដូច្នោះហើយ ក៏ចុះចាកប៉មភាគបន្ទាយ ម្នីម្នាលីលាទៅទូល ស្តេចពារាណសី តាមសេចក្តីនោះសព្វប្រការហើយឲ្យអាមាត្យយក ស្គរជ័យ ទៅវាយប្រកាសប្រាប់ដល់ពួកអាណាប្រជាជនក្នុងព្រះនគរ ឲ្យបើទ្វារកំពែងចេញទៅរើសយកសពសត្វទាំងឡាយនោះមក ធ្វើជាភក្សាហារតាមក្តីប្រាថ្នា ៗ

ឯអ្នកនគរទាំងឡាយ កាលបើបានដឹងបានឮសេចក្តីដូច្នោះ ក៏នាំគ្នា

បើកទ្វារព្រះនគរចេញទៅរើសយកសពសត្វទាំងនោះ មកចំអិនជាភក្សាហារទីទៃៗ សាច់នោះច្រើនណាស់អ្នកខ្លះក៏នាំគ្នាធ្វើផ្អកធ្វើងៀតហាលថ្ងៃទុកអាស្រ័យទៅមុខទៀត តាមក្ដីប្រាថ្នានៃអាត្មាទីទៃៗមានព្ធដ៏កាលនោះហោង ។

រឿងយើងចេះធ្វើសាច់ងៀតសត្វសព្វថ្ងៃនេះអាចារ្យពោលថា គឺចេះអំពីកាលមនុស្សអ្នកពារាណសីធ្វើងៀតសត្វនោះឯង គួរចូលចិត្តហោង ។

រឿងនេះ បានគតិដល់អាមនុស្សចេះសិលវិទ្យាគម សំដែងបញ្ចុះបញ្ចូលអ្នកក្រៅអ្នកព្រៃ បង្កឡើងជាកងទ័ព តាំងក្បត់នឹងម្ចាស់ផែនដីដូចយ៉ាងអាចារ្យស្វា អាចារ្យសុក អាចារ្យជ្រា អាពោកំបោរ អាសៅសិល្បនោះឯង គួរចូលចិត្តចុះ ។

ឯកំលាំងឫទ្ធិសិល្បវិទ្យាគមនោះ ជួយបានតែមួយគ្រាៗជារបស់ឫទ្ធិឈានលោកិយ នឹងទៅឈ្នះម្ចាស់ផែនដី ដែលលោកមានបុណ្យបារមីបានកសាងការកុសលមកអំពីព្រេងនោះ ឯណាបាន ហើយសិល្បនោះអាស្រ័យតាំងនៅបាន ក៏ព្រោះមានបញ្ញាអាចពិចារណាមើលកល មើលការណ៍ផង ទើបនុងរឿងទៅបានដូចយ៉ាងស្ដេចចចកមានតែឫទ្ធិ តែឥតបញ្ញាមិនដឹងជាអាសនាដែលខ្លួនជិះនោះវានឹងជាអាវុធ



សំលាប់ខ្លួនវិញ បាននូវក្ដីបរាជ័យស្លាប់ខ្លួនឯងដូចសំដែងមកនេះ ប្រាជ្ញមានបញ្ញាគួរពិចារណាតាមតំរានេះទៅចុះ ។

ចអើយចចក ចចើងចង់យក សម្បត្តិមនុស្សលោក ខ្លួនជាតិរច្ឆាន មិនមានប្រយោគ ទៅអាងសិទ្ធិជោគ ជ័យមន្តវេទ្យា ។ ប្រើរាជសីហ៍ស្រែក មនុស្សផងបែកត្រចៀកមរណា មិនដឹងសីល៍ស័ក្ខទីនាំងអាត្មា ត្រឡប់ប្រែជា នាំទុក្ខលើខ្លួន ។ ពាលអើយពាលពិត ទៅអាងតែឫទ្ធិ មិនគិតឲ្យធ្ងន មើលយល់តែឆ្ងាយ វៀងអាយជិតខ្លួន មិនយល់កលក្បួន ស្លាប់ដោយក្បាច់ឯង ។ ធម្មតាប្រាជ្ញប្រាយ យោគយល់ជិតឆ្ងាយ យល់ខ្លីយល់វែង យល់ការគួរធ្វើ ឬការគួរលែង ទើបលោកចាតចែង ការនោះមិនបង់ ។

**ចប់តំរាឡើងមានៈតំកើងយស ជាគតិទី ៦៧។**

## រឿងនន្ទកយក្សជាអ្នករក្សាខ្លោងទ្វារព្រះឥសូរ

មានយក្សមួយឈ្មោះនន្ទកៈ ជាអ្នករក្សាខ្លោងទ្វារវាំងព្រះឥសូរ ក្បាលទំពែក សក់មាននៅតែជាយគ្រែងជាទីនាំឲ្យអស់ពួកទេវបុត្រ ទេវតា នាគយក្ខទាំងឡាយចូលចិត្តលេងចំអកចំអន់ទៅផ្សេងៗ ពួកទេវបុត្រ ទេវតា នាគ យក្ខ តែឡើងមកគាលព្រះឥសូរកាលណា សឹងនាំគ្នាទះក្បាល ត្បកក្បាលនន្ទកៈនោះហើយសើចចំអកចំអន់លេង

ទៅតាមភាសា ហើយទើបចូលទៅគាល់ព្រះឥសូរឯក្នុងព្រះរាជមន្ទីរតែយ៉ាងនេះសព្វៗកាលមក ។

ឯនន្ទកៈនោះ ជាយក្ខឥតឫទ្ធិចេស្ដាត្រូវពួកទេវតា ទះក្បាលត្បកក្បាលដូច្នោះក៏ខឹងចិត្តគិតថា បណ្ដាពួកទេវតាទាំងឡាយដែលមាក់ងាយអញយ៉ាងដូច្នេះក៏ព្រោះអញជាអ្នកថោកទាប ឥតឫទ្ធានុភាពដូចគេ បើដូច្នេះគួរអញចូលគាល់ សូមពរព្រះឥសូរជាម្ចាស់ឲ្យព្រះអង្គប្រោសប្រសិទ្ធិចង្កូលដៃអញ ឲ្យកើតជាចង្កូលដៃពេជ្រឡើង អញនឹងចង្កូលពួកអាអស់នេះឲ្យវាធ្លាក់ទៅញឹ៍ចក្រវាឡក្រៅ ទើបសមមុខវា ដែលវាមាក់ងាយអញត្បកក្បាលអញនេះគិតហើយនន្ទកៈក៏ចូលទៅគាល់ព្រះឥសូរ ដល់ហើយក៏ក្រាបបង្គំទូលថា "ខ្ញុំព្រះករុណាចូលមកជាបាទ រក្សាទ្វារព្រះរាជវាំងល្អងធូលីព្រះបាទនេះ ក៏យូរឆ្នាំណាស់ហើយពុំដែលបានរបស់ព្រះរាជទានអ្វីមួយយ៉ាងឡើយ ឥឡូវនេះពួកទេវបុត្រ ទេវតា យក្សទាំងឡាយ គេមាក់ងាយទះក្បាលត្បកក្បាល ខ្ញុំល្អងធូលីព្រះបាទតែរាល់ៗកាល ខ្ញុំល្អងធូលីព្រះបាទបានក្ដីក្ដៅក្រហាយពេកណាស់ សូមទានម្ចាស់ប្រោសប្រោណប្រទានពរដល់ខ្ញុំព្រះករុណាបានមួយយ៉ាង គឺប្រោសប្រសិទ្ធិចង្កូលដៃស្ដាំខ្ញុំព្រះករុណានេះ ឲ្យកើតជាម្រាមពេជ្រសំរេចដោយឫទ្ធិអាចនឹងចង្កូលពួកអាសា



មាន្យអស់នោះឲ្យវាតែខ្ទាត់ខ្ទាយទៅឆ្ងាយអំពីកាយខ្ញុំព្រះករុណានេះ ទើបខ្ញុំព្រះករុណានេះ បាននៅធ្វើរាជការបំរើល្អងធូលីជាសុខសប្បាយតទៅ" ។

ឯព្រះមហិស្សរាធិបតី កាលបើបានស្ដាប់ពាក្យនន្ទកៈដូច្នោះហើយ ក៏អាណិតនន្ទកៈនោះទើបទ្រង់ចាប់ចង្កូលដៃស្ដាំនន្ទកៈលើកឡើងសូត្រប្រសិទ្ធិដោយឫទ្ធិព្រះសយម្ភូមួយរំពេចឡើង ឯចង្កូលដៃនោះក៏កើតជាពេជ្រដូចចិត្តប្រាថ្នានៃនន្ទកៈនោះឯង ។

ឯនន្ទកៈនោះកាលសំរេចក្ដីប្រាថ្នាខ្លួនហើយ ក៏ក្រាបលាព្រះឥសូរចេញមកនៅរក្សាទ្វារដូចប្រក្រតីមុន ហើយតាំងចង្កូលពួកទេវបុត្រទេវតា ដែលមកលលេងត្បកក្បាលខ្លួននោះ ឲ្យអណ្ដែតខ្ទាត់ទៅចក្រវាឡនាយតែរឿយៗរាល់ៗថ្ងៃ ។

ពួកទេវតានាគយក្ខទាំងឡាយ សឹងខ្លបខ្លាចចង្កូលដៃនន្ទកៈនោះគ្រប់ៗគ្នាឯនន្ទកៈសោតក៏ចេះតែចង្កូលមិនថាទេវតាអង្គណាឡើយ និមិត្តតែឃើញហោះមកពីចម្ងាយ ក៏ចង្កូលឲ្យធ្លាក់ទៅ ចក្រវាឡទាំងអស់ ឯពួកទេវតាអស់នោះសឹងភិតភ័យខ្លាចនន្ទកៈគ្រប់ប្រាណពុំហ៊ានចូលមកគាល់ព្រះឥសូរសោះឡើយ ទីជំនុំព្រះឥសូរស្ងាត់ឈឹងចាប់ដើមអំពីថ្ងៃនោះមក ។

ការនោះពុំបាត់ស្វាត់ឡើយ ក៏ជ្រួតជ្រាបដល់ព្រះឥសូរៗក៏កើត ក្តីតក់ស្លុតព្រួយព្រះហឫទ័យដោយក្តីគិតឃើញថា អាត្មាឲ្យពរដល់ នន្ទក:នោះជាការហួសប្រមាណណាស់ នេះនន្ទក:វាចង្កូលតែពួកទេវតា ក្រៅៗ ប្រសិនណានន្ទក:វាគិតក្បត់នឹងអាត្មាវាចង្កូលរូបអញកាលណា អញក៏នឹងអណ្តែតខ្ទាត់ទៅឯចក្រវាឡនាយពុំខាន សម្បត្តិរាជស្ថាន អញក្នុងភ្នំកៃលាសនេះ នឹងបានទៅនន្ទក:វាយកជារបស់វាប្រាកដ អេះ ការនេះនឹងស្ងៀមនៅពុំបាន ចាំគិតអានយករូបវាចេញ ទើប ក្តីសុខអញនឹងមានតទៅៗ ព្រះឥសូរគិតដូច្នោះហើយ ទើបឲ្យទៅ អញ្ជើញព្រះនារាយណ៍ថាព្រះអនុជចូលមកគាល់ខាងក្នុងៗ

ព្រះនារាយណ៍ ក៏ឡើងទៅគាល់ព្រះឥសូរៗក៏ត្រាស់ប្រាប់រឿង នន្ទក: បានចង្កូលដែកពេជ្រជាអាវុធវិសេសនោះសព្វប្រការ ព្រះនារាយណ៍បានស្តាប់ដូច្នោះក៏ទូលថា ព្រះជេដ្ឋាមានពរហើយ មិនពិចារណា ឲ្យយល់ការអន្តរាយនឹងមានដល់ខ្លួន ឥឡូវនឹងទៅដកទៅស្រូបយក វិញឯណាក៏បាន ដ្បិតការវាហួសទៅហើយ ដូច្នេះមានតែគិតកែឧបាយសម្លាប់វាចេញទើបបាន ទូលហើយព្រះនារាយណ៍ ក៏ទទួលយកអាសាទើបបង្គំលាព្រះមហិស្សរាធិបតី ចេញមកខាងក្រៅព្រះរាជមន្ទីរ ហើយនិម្មិតកាយប្លែងកាយក្លាយជាស្រីក្រមុំសមសោភា លីលាកែក្រាយ



ដើរចូលទៅកាន់សំណាក់នៃចៅនន្ទក:នោះឯង ដល់ហើយក៏ប្រើឫកពាកិរិយាឆៀងចុងភ្នែក ដើមភ្នែក ក្រឡេកគន់មុខនន្ទក:ធ្វើអាការ ដូចជាស្រីអ្នកលេងគប់ប្រុស ញ៉ាំងនន្ទក:ឲ្យស្នេហាក្នុងលោកិយដោយប្រការផ្សេងៗឯនន្ទក: បែរទៅឃើញនារាយណ៍នារីគួរជាទី ស្នេហានោះ ក៏ពុំដឹងជានារាយណ៍កាឡា នឹកស្មានថានារីពួករបាំជាប្រាកដទើបកើតក្តួចចិត្តប្រតិព័ទ្ធ ស្រឡាញ់ខ្លាំងក្នុងរូបនារាយណ៍កាឡា នោះហើយក៏ប្រើកិរិយាញញឹមរីករាយនិយាយប្រលោមលួងលោម ដោយពាក្យកំណាព្យឆ្លើយឆ្លងថា "កែវអើយកែវស្នេហ៍បែរមក ណេះ បងសូមសំណេះសំណាលផង ទៅណាមកណាណ៎ាកែវបងរូបចៅ គួរចងចិត្តមេៗ បងអើយបងសួរគួរតបសងគួរស្នាលគួរស្នងគួរបេតី ប្អូនមកនេះគឺស្វែងរកប្តី ត្រូវចិត្តប្អូនស្រីនឹងរ៉ាប់រងៗ កែវអើយ កែវតបកល្យាណីចៅមកទើសប្តីនឹងស្នាលស្នង ទើសរូបយ៉ាងណាៗផ្ទួនល្អង យ៉ាងបងតើគាប់ចិត្តឬទេៗ ប្រុសអើយប្រុសប្រស់ស្រស់ប្រិមប្រិយ៍ ប្អូនស្វែងរកប្តីបេះរាំរេ បើប្រុសបេះរាំបានដូចគេ ប្អូនក៏រាប់ ស្នេហ៍យកជាប្តីៗ មាសអើយមាសមានរូបល្អឯក ត្រង់ការរាំរែកក្បាច់ម្តេចក្តីបងអាចរាំបានទេប្អូនស្រី ក្រអ្វីចូរស្រីរាំទៅរ៉ា សីមបងរាំ តាមមិនឲ្យខុស បំណាច់ជាប្រុសមានបញ្ញា រៀនមកពីគ្រូអស់តម្រា

អញ្ជើញកល្យាណំនាំទៅអើយៗ៕

ឯព្រះនារាយណ៍កាឡា បានឮនន្ទកៈទទួលរាំតាមដូច្នោះ ក៏រេកាយរាយក្បាច់ចាក់លាតហើយកួចចង្កូលដៃស្តាំចង្កូលចុះចំត្រង់ដើមភ្លៅនៃអាត្មា៕

ឯនន្ទកៈក៏រាំតាមចង្កូលតាមនិមិត្តតែចង្កូលដៃពេជ្រនោះត្រូវចំភ្លៅកាលណា ភ្លៅនន្ទកៈក៏បាត់ដួលធ្លាក់ចុះក្នុងទីនោះមួយរំពេច៕

ឯព្រះនារាយណ៍ ក៏ប្រែកាយជានារាយណ៍រឿងរិទ្ធិចតុករ គឺមានហត្ថា៤កាន់ចក្រ ស្ទុះទៅចាប់ក្បាលនន្ទកៈសង្កត់ចុះ ងាចក្រឡើងប្រហារនន្ទកៈនោះឯងឯនន្ទកៈបែរទៅឃើញព្រះនារាយណ៍ដូច្នោះក៏ទោមនស្សតូចចិត្តគិតថា អាត្មាចាញ់ព្រះនារាយណ៍បញ្ឆុកបញ្ឆោតប្លែងជារូបស្រីឲ្យអាត្មាលុះលង់បង់គំនិត៕ នន្ទកៈខឹងខាំមាត់បែរពោលទៅថា "យើៗយើងខុសស្មៀតសត្រូវចូលបៀតបាន ឱព្រះអង្គអើយ ឡើយចុះ ធ្វើម្តេចឯងមានដៃតែពីរ នឹងទៅតស៊ូនឹងព្រះអង្គ៤ ព្រះករឯណាបានបើប្រសិនជាដៃពីរដូចគ្នាខ្ញុំមិនទទួលចាញ់ព្រះអង្គទេ"៕

ឯព្រះនារាយណ៍បានឮពាក្យនន្ទកៈដូច្នោះ ក៏ត្រាស់ថា "ជាតិនេះយើងដៃ៤ ចៅដៃតែពីរ ទើបចាញ់យើងបើដូច្នេះ ចៅឯងទៅកើតនាស្ថានមនុស្សលោកនាយឲ្យមានមុខ១០ដៃ២០ចុះយើងចុះទៅកើត



ជាមនុស្សមានដៃតែពីរវិញ នឹងតស៊ូគ្នាទៅខាងមុខទៀត"៕

ព្រះនារាយណ៍ត្រាស់ហើយ ក៏ប្រហារជីវិតនៃនន្ទកៈនោះដោយកង់ចក្រវិសេសហោង៕

ដោយឮថា នន្ទកៈនោះមកកើតជាក្រុងរាពណាសូរជាស្តេចយក្ខនៅកោះលង្កា ព្រះនារាយណ៍បែងភាគចាករូបចាស់នៅឆ្នេរមហាសាគរ មកកើតជាអង្គព្រះរាមា បានធ្វើសឹកនឹងគ្នាជាអធិកខ្លាំងក្រៃមានសេចក្តីពិស្តារនៅក្នុងសាស្ត្រារឿងរាមកេរ្តិ៍ឯណោះអញ្ជើញទៅមើលចុះ៕

ខ្ញុំបាទទាញរឿងដើមតែប៉ុណ្ណេះនេះ ដើម្បីឃើញជាគតិថា នន្ទកៈនោះស្លាប់ដោយចង្កុយដៃរបស់ខ្លួន បានគតិបុគ្គលអ្នកប្រាជ្ញព្រោកនិយាយអួតតែខ្លួនឯង ចង្កូលតែខ្លួនឯងសរសើរតែខ្លួនឯងបុគ្គលណាអួតសរសើរតែខ្លួនឯងហើយ បុគ្គលនោះនឹងលុះសេចក្តីនិន្ទាអ្នកដទៃ បានសេចក្តីវិនាសដូចនន្ទកៈនោះឯង ប្រាជ្ញមានបញ្ញាគួរគិតទៀតចុះ៕

នន្ទអើយនន្ទកៈ បានព្រះនាយក ជ្រលក់អង្គុល កើតជាម្រាមពេជ្រសំរេចឫទ្ធិ ចង្កូលពួកនី-ករទេពខ្ចាត់ខ្ចាយ៕ ចៅអាងម្រាមដៃ ឥតធ្យាស្រ័យ ដល់ទេពទាំងឡាយ កៅដល់សូលី កោសីចៅហ្វាយ ប្រើឲ្យព្រះនារាយណ៍ កំចាត់ចៅបង់៕ ចៅបង់ជីវិត ព្រោះដោយឥទ្ធិឫទ្ធិ

ភ្លើងរាគទោលអង្គ ឃើញតែរូបស្រី ចំណីនៃសំ សារត្រូវក្ដីបង់ប្រាណព្រោះមិនឃ្លេង។ លុះលង់ភ្លើងកាម ទៅទេវាំតាម នារាយណ៍ វាំក្លែង វាំក្បាច់ផ្កាផ្កុល ចង្កុលភ្លៅឯង ដួលបាក់ប្រខែង ចៅឯងកង្រៃណ កង្រ័យ។

**ចប់តម្រាស្លាប់ដោយម្រាមដៃឯងជាគតិទី ៦៨។**

## រឿងស្វាព្រាម១ បានមេស្វាអូវ១ ជាភរិយា

មានស្វាព្រាមមួយ ទៅបានមេស្វាអូវជាភរិយាស្វាព្រាមនោះនាំមេភរិយាចេញចាកពួកស្វាអូវទាំងឡាយដែលជាញាតិនៅទីជើងភ្នំ ស្វាព្រាមនោះស្រឡាញ់មេភរិយាក្រៃពេក តាំងថ្នាក់ថ្នមពុំឲ្យទៅរកស៊ីនៅទីឯណាឡើយ ស៊ូទៅបេះផ្លែឈើឬអាហារឯណាដែលមេនោះចង់ស៊ី ហើយក៏ឧស្សាហ៍នាំមកចិញ្ចឹមភរិយានោះតែសព្វៗថ្ងៃ។ ដើរទៅដល់ទីស្វាព្រាមនោះឯង ថ្ងៃនោះស្វាព្រាមទៅស្វែងអាហារឯព្រៃភ្នំ នៅតែមេភរិយាចាំទី ឯមេនោះកាលឃើញស្វាឈ្មោលជាជាតិខ្លួនមកដល់ដូច្នោះ ក៏កើតក្ដីស្នេហាស្រឡាញ់ចង់រួមផ្លូវវេណីតាមជាតិខ្លួន ទើបសាកសួរដោយមាយាទៅថា "ហៃអ្នកកំលោះ អ្នកដើរមកនេះ តើមកអំពីទីស្ថានណា អ្នកមកនេះ តើមានបើប្រាថ្នារកអ្វីហះ?។



ឯស្វាឈ្មោលបានឮពាក្យមេនោះសួរដូច្នោះ ក៏គិតថាមេនេះជាជាតិជាមួយនឹងអញ អញមកដល់ទីនេះពុំមានស្គាល់នរណាមួយឡើយគួរហើយនឹងនិយាយប្រលោមឲ្យស្និទ្ធទុកជាមិត្រជាញាតិ នឹងបានជាទីពឹងទៅខាងមុខ គិតហើយក៏ពោលតបទៅថា "ឱនាងអើយ! ខ្លួនខ្ញុំនេះវង្វេងផ្លូវព្រៃដើរស្វែងរកពួកញាតិមិត្រជាជាតិដូចគ្នា ក៏ពុំប្រទះនរណាមួយឡើយទើបតែថ្ងៃនេះ ជាបុញ្ញលាភបានមកប្រទះលើនាងជាជាតិដូចគ្នានេះ អើនាង! ហេតុម្ដេចបានជានាងនៅតែឯងអ្នកជាប្រុសតើគាត់អញ្ជើញទៅឯណាមួយទៀតនាងជាជាតិស្វាអូវតែងនៅដោយព្រៃនាមនេះ ហេតុអ្វីមកនៅៗនេះតែឯងដូច្នេះ"។

មេស្វាឆ្លើយថា "ខ្ញុំមានប្ដីជាជាតិស្វាព្រាមបានជាតាមកនៅក្នុងទីនេះ ឥឡូវគាត់ទៅស្វែងរកអាហារហើយ ចុះអ្នកកំលោះឯងនឹងគិតទៅឯណា?។

ស្វារអូវក៏ឆ្លើយប្រាប់ថា "ខ្ញុំនេះមិនកំណត់ទេ ចិត្តចង់នៅនាទីនេះដែរ តែខ្លួនម្នាក់ឯង ពុំមានញាតិមិត្រឯណាមួយជាទីពឹងពាក់អាស្រ័យសោះ គិតថាបើមានទីពឹងពាក់អាស្រ័យបាន ក៏នឹងនៅរកស៊ីនឹងគេទៅជាបើពុំមានទេ នឹងវិលទៅលំនៅដើមខ្លួនវិញ។

ឯមេស្វានោះមានចិត្តស្រឡាញ់ស្វាអូវនោះខ្លាំងណាស់ក៏ទទួលពាក្យ

ថា "អ្នកឯងចូរនៅទីខ្ញុំនេះចុះតែអ្នកឯងឆ្លើយថាជាក្មួយខ្ញុំ មកសួរសុខទុក្ខខ្ញុំ យ៉ាងនេះទើបឥតក្តីវង្វេស ឥឡូវនេះប្តីខ្ញុំទៅព្រៃស្វែងអាហារពុំទាន់មក បើគាត់មកកាលណាចូលបាឯងហៅគេលោកមាៗចុះ យើងប្រាប់ប្តីយើងថា បាឯងជាក្មួយមកតាមយើង មកសួរយើងៗនឹងឲ្យចៅឯងនៅជាមួយផង កុំឲ្យប្តីយើងគាត់មានចិត្តវង្វេសសង្ស័យនឹងចៅឡើយ ថាហើយមេស្វាប្រាប់ឈ្មោះម្តាយឪពុកនឹងឈ្មោះញាតិសន្តានឯណោះ ឲ្យចៅពានរនោះចាំឈ្មោះទាំងអស់ ដើម្បីប្តីសួរសុខទុក្ខដល់វង្សញាតិនឹងប្រាប់ឲ្យត្រូវឲ្យប្តីជឿចិត្តថា ជាកូនក្មួយខាងប្រពន្ធមែន មេស្វាប្រាប់ការនោះស្រេចហើយ ក៏នាំចៅពានរនោះចូលទៅក្នុងរូងភ្នំជាលំនៅខ្លួន ហើយសំដែងកិរិយាមាយាញ៉ាំងចិត្តចៅពានរឲ្យទប់ពុំបាន ចៅពានរក៏ចូលរួមចង្វាសសេពមេថុននឹងមេនោះឯងលុះរួចកិច្ចនោះហើយ ចៅពានរក៏ចេញមកខាងក្រៅៗ

លុះដល់ពេលល្ងាច ស្វាព្រាមជាប្តីមកដល់មេនោះក៏ធ្វើជាមាយាប្រើកិរិយាដូចជាគេត្រេកអរនឹងប្តីក្រៃពេក គឺស្ទុះទៅទទួលប្តីហើយស្រដីថា ថ្ងៃនេះខ្ញុំនឹកដល់អ្នកណាស់ ព្រោះក្មួយយើងទើបនឹងមកដល់បានដំណឹងអំពីពួកញាតិយើងថា សុខសប្បាយជាទាំងអស់គ្នាទេៗ

ឯស្វាព្រាមពុំដឹងកលមាយាមេប្រពន្ធក៏នឹកស្មានថាមែនពិត ទើបសួរទៅថា ចុះក្មួយនោះនៅឯណាទៅហៅមកមើលមេស្វាក៏ចេញទៅ



ហៅអាសហាយនោះមក អានោះមកក៏សំពះសួរតាមភាសាទើបស្វាព្រាមសួរដំណឹងពីពួកញាតិ ខាងប្រពន្ធនោះតាមក្តីដែលប្រាសមក នៅឆ្ងាយ ឯចៅពានរនោះក៏ប្រាប់តាមសេចក្តី គឺស្វាព្រាមនោះសួរដល់ឈ្មោះណាចៅពានរក៏ប្រាប់តាមឈ្មោះនោះពុំឲ្យខុសឡើយ ៗ

ចៅស្វាព្រាមបានឮចៅពានរប្រាប់ឈ្មោះវង្សញាតិត្រូវចំឈ្មោះដូច្នោះ ក៏អស់ក្តីសង្ស័យជឿថាជាញាតិខាងប្រពន្ធខ្លួនពិត ទើបនិយាយថា "អើក្មួយឯងបានមកដល់ទីយើងនេះហើយ ក៏ចូរនៅរកស៊ីនឹងយើងចុះ បើចង់ទៅស្រុកវិញកាលណាចូរប្រាប់មាៗជូនទៅ" ៗ ថាហើយក៏រៀបទីឲ្យចៅពានរនោះនៅក្នុងរូងថ្មជាមួយអាត្មា ហើយតែងនាំស្វាអូវនោះទៅស្វែងរកចំណីព្រៃ នាំមកចិញ្ចឹមគ្នាតាមភាពស្វាពានរហោង ៗ ឯមេស្វានោះក៏លបលាក់សហាយនឹងអាស្វាអូវនោះជាប្រក្រតី ចៅស្វាព្រាមជាប្តីពុំដឹងកលមាយានោះឡើយ ដោយការទុកចិត្តថាជាញាតិជាក្មួយខ្លួន ឯស្វាទាំងពីរតាំងពីបានរួមរសកាមសង្វាសនឹងគ្នាក៏កើតចិត្តស្អប់ប្តី គិតនឹងលួចទ្រព្យរបស់ឲ្យបានច្រើនហើយនាំគ្នារត់បោលស្វាព្រាម ទៅនៅព្រៃនាមវិញ ៗ មានកាលថ្ងៃមួយមេនោះក្លែងធ្វើជាឈឺពុំសប្បាយ តាំងដេកនៅពុំនាំពាក្លែងមាយាប្រាប់ប្តីថា "ខ្ញុំេះតាំងពីកូនក្មួយមកនៅផង ក៏ពុំចេះជាឡើយតែងក្តៅក្រហាយរសាប់រសល់ ស៊ីពុំបានដេកពុំបានកើតរំខានខ្លាំង ខ្ញុំបានទៅ

រកហោរគន់គូរមើល គេថាត្រូវខាងខ្មោចដូនតាមេបាខឹង ព្រោះកូនក្មួយមកដល់មិនគិតសែនព្រែនទទួលខ្មោច ហេតុដូច្នេះចូរអ្នកមេត្តាប្រពន្ធចុះ ចូរអ្នកទៅព្រៃស្វែងរករកឃ្មុំផ្លឹតបានមួយសំបុកយកមកសែនដូនតាឲ្យខ្ញុំ ព្រោះដូនតាខ្ញុំគាប់ចិត្តតែនឹងឃ្មុំផ្លិត ទាល់តែមានឃ្មុំផ្លឹតទើបទទួលសំណែននោះ នឹងធ្វើឲ្យបានជាសុខសប្បាយតទៅហើយថ្ងៃនេះ កុំឲ្យក្មួយវាទៅព្រៃផងឡើយ ទុកឲ្យវានៅជួយមើលផម្ទឹខ្ញុំ" ៗ ឯស្វាព្រាមពុំដឹងកលមាយាប្រពន្ធឡើយ ក៏ជឿតាមហើយឲ្យអាក្មួយនៅរក្សាមីង ខ្លួនឯងក៏ចេញទៅស្វែងរកឃ្មុំហោងៗ

ឯមេនោះ កាលប្តីទៅបាត់ហើយក៏សប្បាយនឹងអាសហាយតាមកាលស្ងាត់ វានាំគ្នាទើយករបស់ទ្រព្យយ៉ាងល្អៗ វេចស្ពាយហើយនាំគ្នារត់ចោលទីប្តីទៅនៅព្រៃរនាម តាមក្តីប្រាថ្នាវាហោងៗ

លុះដល់ពេលល្ងាច ស្វាព្រាមមកដល់រូងវិញស្រាប់តែស្ងាត់ឈឹងរកមើលរបស់ទ្រព្យខ្លួនបាត់អស់រលីង ស្វាព្រាមក៏ដឹងថា អានោះមេនោះវាពង្រត់គ្នាទៅចោលខ្លួនហើយ ស្វាព្រាមបានក្តីក្តៅក្រហាយដោយចាញ់កលមាយាស្ត្រី ជាការធ្វើឲ្យបុរសដឹងមិនដល់បាន ជាការធ្វើឲ្យបុរសលុះលង់បង់ប្រាណ មានសភាពដូច្នេះហោងៗ

រឿងនេះ បានគតិដល់ស្រីជួបបានប្តីជាតិដទៃអំពីជាតិខ្លួន ហើយទោះប្តីនោះស្រឡាញ់ថ្នាក់ថ្នមឲ្យសម្បត្តិយ៉ាងណាក៏ដោយ តែឃើញ



ប្រុសជាតិខ្លួនហើយក៏កើតត្រេអរនឹងជាតិខ្លួនវិញ គឺបែរទៅស្រឡាញ់ប្រុសជាតិជាមួយ ដូចមេស្វាអូវទៅសហាយនឹងអាស្វាអូវចោលស្វាព្រាមប្តីដើមនោះឯងៗ

មួយទៀត មាយាស្រីខូចនោះជាការជ្រៅពេកណាស់ក្រមបុរសជាប្តីនឹងដឹងដល់ ដូចយ៉ាងមេស្វាអូវវាប្រចុបប្តីឲ្យជឿថាជាកូន ជាក្មួយជាញាតិសន្តានធ្វើឲ្យប្តីអស់ក្តីរង្កៀស អស់ក្តីសង្ស័យយកអាសហាយឲ្យនៅជាមួយផងបាន មួយទៀតស្រីខ្លះវាចេះបង្រួមទៅលើម៉ែឪវិញក៏មាន ដូចនិទានបុរាណមានមកថា ៖ កាលនោះមានត្រកូល១តាំងលំនៅៗខាងផ្លាផ្សារធំប្រជុំមនុស្សច្រើន ត្រកូលនោះមានកូនប្រុសស្រីម្នាក់ មេនោះជាស្រីអ្នកលេងគប់ប្រុសសហាយវា ចេះរកឧបាយបិទមិនឲ្យប្តីដឹង កាលណាវាចង់ដេកនឹងសហាយ វាឲ្យអាសហាយនោះមកដេកចាំនៅរានខាងជ្រុងរបងផ្ទះ លុះដល់រាត្រីស្ងាត់ប្តីដេកលក់ វាក៏លបចុះទៅដេកនឹងសហាយនោះឯងៗ

ថ្ងៃមួយក្នុងពេលយប់ចូលជាមជ្ឈិមយាម តាព្រាហ្មណ៍ជាអាពុកក្មេកចុះទៅបង្គន់ ដោយគាត់ហើមពោះ គាត់អុជទៀនកាន់ដើរទៅដល់រាននោះ បានឃើញមេកូនប្រសាដេកឱបប្រុសសហាយ ទើបគាត់គិតថា អញនឹងស្រែកឡូឡាឡើងក្នុងកាលឥឡូវនេះយល់មិនគួរ អញគិតយកតែរបស់សំខាន់ទុកឲ្យកូនអញវាមើលជាភស្តុតាងចុះ

តាព្រាហ្មណ៍ដើរលបៗទៅដោះយកកងជើង អំពីជើងមេកូនប្រសានោះបានម្ខាង ហើយក៏វិលមកឡើងផ្ទះដោយប្រញាប់មិនទាន់បានប្រាប់ឲ្យគេឯងនៅជិតខាងដឹងឮឡើយ គាត់ក៏យកកងនោះដាក់ក្នុងប្រអប់ស្លា។

ឯមេនោះក្នុងខណៈដែលដេកនឹងប្រុសសហាយហើយ ដែលអាពុកក្មេកដោះយកកងជើងនោះ វានឹងបានដេកលក់ក៏ទេ វាដឹងឪពុកក្មេកមកដោះយកកងដែរ តែវាក្លែងសម្ងំធ្វើជាលក់ដោយអៀននឹងអាពុកទាន់ លុះអាពុកទៅផ្ទះហើយទើបវាដាស់ប្រុសសហាយនោះ ឲ្យក្រោកឡើងប្រាប់វត់ទៅ ខ្លួនវាក៏ត្រឡប់ឡើងទៅលើផ្ទះ ចូលទៅដេកនឹងប្ដីហើយដាស់ប្ដីឲ្យភ្ញាក់ឡើង ទើបវាក្លែងពោលថាក្ដៅណាស់ដេកមិនលក់ទេ ហើយវាបបួលចៅប្ដីទៅដេកនៅរានខាងរបងផ្ទះដែលវាដេកនឹងប្រុសសហាយនោះ លុះដល់ពេលទៀបនឹងភ្លឺ មេនោះវាក្លែងស្រែកឡូឡាឡើងថា ហេតុអ្វីមកកំហែងខ្ញុំតែផ្ទាសដូច្នេះ។

ឯចៅប្ដីបានឮដូច្នោះ ក៏ភ្ញាក់ឡើងភិតភ័យតក់ស្លុត ទើបសួរភរិយាៗប្រាប់ថាខ្ញុំនឹងអ្នកដេកនៅនេះបិតាអ្នកជាមនុស្សចាស់ទុំពុំមានក្ដីអៀនខ្មាស់ ចុះមកចាប់ជើងខ្ញុំដោះយកកងជើងខ្ញុំទៅ។

ឯចៅប្ដីបានស្ដាប់ពាក្យភរិយាថាដូច្នោះ ក៏ខឹងនឹងអាពុកខ្លួន ទើបម្ទីម្នាឡើងទៅលើផ្ទះ ហើយនិយាយនឹងអាពុកថា "គួរឬ, ឪឯងធ្វើអំពើ



មិនគួរយ៉ាងនេះ"។ ឯបិតាក៏បើកប្រអប់យកកងមកឲ្យកូនមើល ហើយប្រាប់ថា "ទេវិលាយប់មិញនេះ ភរិយាចៅឯងវានាំប្រុសសហាយមកដេកនៅលើរានខាងផ្ទះ វាដេកលក់ទាំងពីរនាក់ អញចុះទៅឃើញអញគិតថានឹងស្រែកឡូឡាឡើង ខ្លាចវាបានក្ដីខ្មាសអស់ពួកអ្នកស្រុក ទើបអញដោះយកតែកងជើងម្ខាងជាទីអាងមកទុកឲ្យកូនឯងមើលជាសាក្សី", បិតានិយាយមិនទាន់អស់សេចក្ដី កូនមិនជឿក៏ពោលកាត់ថា "ខ្ញុំបានប្ដីនឹងប្រពន្ធនាំគ្នាចុះទៅដេកនៅរាននោះ ឪឯងជាមនុស្សចាស់មិនពិគ្រោះមើលឲ្យមែនទែន ចូលទៅលួចដោះយកកងប្រពន្ធខ្ញុំ ហើយមកពោលដាក់ទោសកូនប្រសាថាគប់ប្រុសសហាយ ឲ្យបានក្ដីអាស្រូវបាភយខ្មាសគេយ៉ាងនេះ គួរឬធ្វើជាចាស់មកពាលោពោលចង្កូចគេយ៉ាងនេះ ប្រពន្ធខ្ញុំវាដេកនឹងសហាយឯណាវាដេកនិងខ្ញុំទេតើ"។

ឯបិតានោះ លុះឮកូនថាមិនជឿពាក្យខ្លួនដូច្នោះក៏ស្ងៀម ទើបនិយាយថា "អើយើងជាចាស់មិនពិគ្រោះ ទៅយកអំពើអាក្រក់មកទំលាក់ដាក់លើប្រពន្ធចៅឯងមែន ល្មើយចុះយើងខុសហើយយើងសូមខមាទោសផងចុះ"។

ចៅប្ដីមិនដឹងកលមាយាភរិយាខ្លួយនធ្វើល្មើសគប់ប្រុសសហាយ ហើយក្លែងកំហែងបិតាវិញ បិតាញ្ញុះញ្ញង់បំបាក់បំបែកប្រពន្ធខ្លួន

អស់ក្បួនស្រីមាយាតែត្រឹមនេះ ៗ

មានស្រីខ្លះចិត្តសាវ៉ាប្រព្រឹត្តជួប ហើយត្រឡប់ជាកែខ្លួនវិញក៏មាន ដូចនិទាននាងភរិយាចៅនាយសំពៅម្នាក់នៅស្រុកយាវ័ណទ្វីតី ថ្ងៃមួយ នាយសំពៅចេញទៅជួញនាស្រុកឆ្ងាយ ទុកនាងភរិយាឲ្យនៅរក្សាគេហដ្ឋាន ៗ

ឯនាងភរិយានោះលុះនាយសំពៅជាប្តីទៅជួញយូរខែពុំទាន់មក មានចិត្តរំជួលដោយរាគកិលេសក្រៃពេក ទើបគបប្រុសសហាយនាំមកដេកលើផ្ទះធ្វើសមគ្គសង្វាសរាល់ទិវារាត្រី បិទក្តីជួនោះពុំឲ្យអ្នកឯណាមួយដឹងឮឡើយ ឯនាយសំពៅទៅលក់ដូរយូរអស់កំណត់ហើយក៏ត្រឡប់មកវិញ ឡើងពីសំពៅដើរទៅដល់ទ្វារផ្ទះស្រែកហៅភរិយាឲ្យបើកទ្វារទទួលខ្លួន ៗ

ឯមេភរិយាកំពុងនិទ្រានឹងប្រុសសហាយនៅលើផ្ទះ លុះបានឮសំឡេងប្តីហៅឲ្យបើកទ្វារដូច្នោះ ក៏ភិតភ័យតក្កមា ទើបខ្សឹបប្រាប់ប្រុសសហាយថា "ស្វាមីខ្ញុំគាត់មកដល់ហើយ អ្នកឯងនឹងចេញទៅឥឡូវនេះយល់ថាបាន ព្រោះស្វាមីខ្ញុំគាត់នៅនឹងជណ្តើរផ្ទះនេះហើយ យល់ជារត់ចេញទៅមិនរួចខ្លួន បើដូច្នេះចូរ អ្នកឯងលូនចូលទៅលាក់ខ្លួនពួនអាត្មា នៅក្រោមគ្រែនេះសិនចុះ ខ្ញុំនឹងចេញទៅទទួលស្វាមី ថាបើស្វាមីខ្ញុំគាត់ចូលមកដេកហើយ សឹមខ្ញុំមកនាំអ្នកចេញទៅ



ជូនឲ្យផុតទ្វារផ្ទះ" ៗ ថាហើយនាងក៏ឲ្យប្រុសសហាយនោះចូលទៅនៅក្រោមគ្រែ បិទបាំងដោយសំពត់ដើម្បីមិនឲ្យនាយសំពៅឃើញប្រុសសហាយ ហើយនាងចេញទៅបើកទ្វារឲ្យស្វាមីឡើងមកលើផ្ទះ នាំប្តីចូលទៅកាន់ដំណេក និយាយចរចាប្រស្រ័យគ្នាអំពីការទៅស្វែងលាភស្រុកឆ្ងាយសព្វប្រការ លុះពេលយប់ជ្រៅនាយសំពៅក៏និទ្រាលក់ទៅ ៗ

ឯមេភរិយានោះវាដេកពុំលក់ឡើយ វារំពឹងគិតថា "ស្វាមីអញនេះគាត់ឧស្សាហ៍ទៅលក់ដូរជួញប្រែខ្វល់ខ្វាយរកទ្រព្យសម្បត្តិមកចិញ្ចឹមអញ គ្មានគិតក្តីហត់នឿយ ក្តីលំបាកឡើយគុណស្វាមីនេះពាក់កណ្តាលនឹងបិតាបង្កើតជាម្តង ដែលខ្លួនអញទៅគប់ប្រុសសហាយផាយជាផិតក្រៅចិត្តស្វាមី ធ្វើក្តីជួលាមកអាក្រក់ដូច្នេះមិនគួរសោះឡើយ បើដូច្នេះគួរគិតកាត់ក្តីអាល័យពីប្រុសសហាយឲ្យដាច់ស្រឡះ គិតហើយក៏លូកដៃស្ទាបកាយស្វាមីមើល ដឹងថាស្វាមីនិទ្រាលក់ស្និទ្ធឥតសង្ស័យ ទើបចាប់យកក្រិះដ៏មុតថ្លាលបយាត្រាចុះចាកគ្រែដេក លូកដៃទៅស្ទាបរកប្រុសសហាយដែលពួននៅក្រោមគ្រែនោះឯង ៗ

ឯអាសហាយដែលក្រាបពួននៅក្រោមគ្រែគ្រាន់តែឮសូរជើងភរិយានាយសំពៅចុះមករកខ្លួន ក៏ត្រេកអរ សំគាល់ថានាយសំពៅដេកលក់ ភរិយានឹងមកទទួលខ្លួនជូនឲ្យផុតអំពីទ្វារផ្ទះតាមសញ្ញា ទើប

វាវារចេញមកពីក្រោមគ្រែ ហើយចាប់ដៃមេសហាយឯមេនោះក៏ចាក់ដោយក្រិះត្រូវបំពង់កផ្លុះរហូតដួលដាច់ខ្យល់ស្លាប់មួយរំពេច ទើបមេនោះយកសំពត់បិទមុខរបួសមិនឲ្យលោហិតចេញច្រើន ហើយលើកខ្មោចនោះផ្អែកពីងនឹងសសរបញ្ឈរទុក ស្រេចហើយក៏ដើរលបៗឡើងទៅដេកខាងប្ដីយកដៃអង្រួនដាស់ប្ដីឲ្យដឹងខ្លួន ហើយក្លែងពោលកលឧបាយឡើងប្រាប់ប្ដីថា ចោរឡើងមកលួចទ្រព្យសម្បត្តិយើងហើយ ៗ នាយសំពៅបានស្ដាប់មេភរិយាប្រាប់ដូច្នោះក៏ស្ទុះក្រោកចាប់លំពែង ចុះចាកគ្រែម្នីម្នារទៅចាក់ខ្មោចនោះដួលចុះនៅទីនោះឯង ឯមេភរិយាលុះក្លែងបញ្ឆោតប្ដីឲ្យចាក់ខ្មោចសហាយហើយ ទើបនិយាយថា "ការដែលអ្នកសម្លាប់ចោរស្លាប់នៅលើផ្ទះនេះពួកមហាជនទាំងឡាយ នៅជិតខាង គេពុំដឹងឮឡើយ ក្រែងការនេះបែកដឹងដល់លោកអញ្ញូនករាជការ ថាយើងសម្លាប់មនុស្សដូច្នេះ ទោសនេះនឹងធ្លាក់ដល់អ្នលដល់ខ្ញុំដូច្នេះ តើអ្នកនឹងគិតបិទបាំងយ៉ាងណាឲ្យសូន្យការនេះ" ៗ

នាយសំពៅបានស្ដាប់មេភរិយាថាដូច្នោះ ក៏ទុញទាល់គំនិតគិតមិនយល់ផ្លូវ ទើបប្រឹក្សានឹងភរិយាថា "សពអាចោរនេះ បើទុកនៅលើផ្ទះយើងតែដល់ពេលព្រឹកឡើង គង់មានគេដឹងឮបែកការដល់រាជការជាប្រាកដ ដូច្នេះតើនាងជួលគិតឲ្យផុតក្ដីអន្តរាយឃើញឧបាយ



ដូចម្ដេចយើងធ្វើតាម" ៗ

ឯមេភរិយាក៏តបថា "ខ្ញុំគិតឲ្យសែងយកខ្មោចនេះទៅចោលក្រោមដើមខ្នុរ ក្នុងវត្តលោកសង្ឃនៅខាងក្រោយភូមិយើងនេះ តែដល់ព្រឹកឡើងព្រះសង្ឃក្នុងអារាមនោះលោកនឹងបបួលគ្នាយកខ្មោចនេះទៅដុតជាមិនខាន ទោះជាការនេះដឹងដល់រាជការក៏គង់ពុំមាននរណាចេញជាតួចោទឡើយ គឺដឹងតែយើងប្ដីប្រពន្ធពីរនាក់ប៉ុណ្ណោះឯង" ៗ

ឯនាយសំពៅ បានស្ដាប់ឧបាយមេភរិយាដូចោះក៏យល់តាម ទើបតបថា "គិតនេះត្រូវល្អហើយ តែយើងនឹងដាស់ពួកខ្ញុំកំដរ ឲ្យវាជួយសែងខ្មោចនេះទៅចោល ក្រែងមិនស្ងាត់បើដូច្នេះនាងគ្រាន់តែជូនបងទៅចុះ ចាំបងពបីខ្មោចនេះទៅ" ថាហើយនាយសំពៅក៏ចាប់ពខ្មោចចេញទៅកាន់អារាម នាងភរិយាតាមទៅជាមួយគ្នា លុះដល់អារាមឃើញដើមខ្នុរធំ១ដើមមានផ្លែច្រើន នាយសំពៅក៏ដាក់ខ្មោចបញ្ឈរផ្អែកនឹងដើមខ្នុរនោះឯង ហើយប្ដីប្រពន្ធក៏នាំគ្នាវិលមកកាន់គេហដ្ឋាននៃអាត្មាវិញហោង ៗ

ថ្លែងឯចៅអធិការវត្តនោះ លុះដល់ពេលទៀបនឹងភ្លឺស្វាង ក៏គ្រងត្រៃចីវរកាន់ឈើប្រស់ចុះចាកកុដិ ដើរបោសអាវាស បោសទៅមកៗ បែរទៅឃើញសាកសពឈរពីងនៅនឹងដើមខ្នុរធំ គិតថាអាចោរលួចខ្នុរ ទើបលោកក្រោធខឹងស្ទុះលបអែបនឹងម្លប់ឈើចូលទៅជិត...

ហើយស្រែកថា អះពះអាកំណាចកាចកិងវាលេងខ្នុរលោកសង្ឃហើយតើ ថាហើយក៏វាតិឈើប្រច់ត្រូវសាកសពនោះដួលចុះស្ងៀមទៅ លោកចៅអធិការក៏ភ័យខ្លួន គិតថាអាត្មាវាយត្រូវត្រង់កន្លែងសំខាន់ ទើបចូលទៅមើល ក៏ដឹងថាមនុស្សត្រូវអាវុធគេ ហើយគេនាំយកមកដាក់ផ្អែកទុកនឹងដើមខ្នុរនេះទើបគិតថា ក្នុងខណៈដែលអាត្មាវាយខ្មោចនេះដួលនោះ អាត្មាបានស្រែកថាអាចោរលួចខ្នុរ ព្រះសង្ឃសាមណេរទំនងជាបានឮហើយ ឥឡូវនេះមនុស្សមកស្លាប់នៅក្រោមដើមខ្នុរនេះ ពួកព្រះសង្ឃសាមណេរក្នុងអារាមមុខជាគេថាអញសម្លាប់ចោរលួចខ្នុរ ទុកជាប្រាប់គេដោយពិតថា ខ្មោចនេះគេយកមកដាក់ពឹងនឹងដើមខ្នុរនេះ ក៏គង់គេមិនជឿគង់គេដិតចិត្តសង្ស័យពិគ្រោះមើល ជាមិនផុតក្ដីមន្ទិលទៅបាន បើដូច្នេះគួរដើរឧបាយកោរសក់ក្បាលខ្មោចនេះហើយសំលៀកបំពាក់ស្បង់ចីពរដូចសាមណេរ ហើយប្រាប់គេឯងឲ្យដឹងថា មានសាមណេរឥតញាតិជាអាគន្តុកកើតរោគបច្ចុប្បន្នស្លាប់ យ៉ាងនេះទើបអញផុតក្ដីមន្ទិលឥតមាននរណាថាអញតទៅៗ លោកចៅអធិការគិតដូច្នោះហើយ ក៏ចូលទៅទាញអូសខ្មោចនោះលើកទៅដាក់លើសាលាកណ្ដាលអារាម ទើបយកសំពត់លឿងមកឃ្លុំរុំព័ទ្ធសពនោះទុកតែមុខ ហើយយកកន្ត្រៃមកកាត់សក់ ទុកតែត្រឹមពាក់កណ្ដាលអង្គុលីដូចយ៉ាងសាមណេរ ដើម្បី



មិនឲ្យនរណាសង្ស័យ លុះអរុណរះឡើងលោកចៅអធិការប្រកាសប្រាប់ភិក្ខុសាមណេរទាំងពួកថា វេលាយប់មិញពេលម៉ោង៤ប្លាយយើងចុះទៅបោសអារាម ឃើញសាមណេរមកដេកស្លាប់នៅលើសាលា មិនដឹងជាមកពីអារាមណាជាសពអនាថាឥតញាតិមិត្រ ធ្លាក់មកនៅអារាមយើងដូច្នេះចូរលោកទាំងឡាយ ទៅឃោស្នាពួកសប្បុរសបណ្ដាដែលមានសទ្ធា មកជួយបូជាសពនេះជាការធ្វើបុណ្យយកបុណ្យទាំងអស់គ្នាៗ

ឯព្រះសង្ឃសាមណេរបានឮពាក្យលោកគ្រូដូច្នោះ ក៏នាំគ្នាទៅឃោស្នាប្រាប់ញាតិញោមទីទៃៗ តាមពាក្យលោកចៅអធិការនោះឯងៗ

ឯមេភរិយានាយសំពៅ លុះវេលាភ្លឺស្វាងហើយក៏អង្គុយនៅមាត់ផ្ទះរង់ចាំស្ដាប់សេចក្ដីនោះ លុះបានឮលោកសង្ឃសាមណេរ ត្រាច់មកឃោស្នាអ្នកស្រុកថា មានសាមណេរឥតមាតាបិតាញាតិកាមកស្លាប់លើសាលាដូច្នោះ ក៏កើតក្ដីសង្ស័យឆ្ងល់ក្នុងចិត្តគិតថា មិនមែនជាសាកសពប្រុសសហាយអញនោះទេដឹង? បើដូច្នេះចាំទៅមើលឲ្យច្បាស់សិនគិតហើយក៏រៀបទៀនធូបស្លាម្លូ លាស្វាមីថានឹងទៅជួយបុណ្យលោកគ្រូ ហើយនឹងស្ដាប់ការណ៍នោះផងៗ នាយសំពៅក៏បើកឲ្យទៅតាមក្ដីប្រាថ្នា មេនោះក៏ចរយាត្រាទៅកាន់អារាម មិនបានឃើញសព...

ប្រុសសហាយ ក៏នឹងមានក្ដីសង្ស័យខ្លាំងទើបឡើងទៅលើសាលាដែលដំកលសព ហើយបើកសំពត់គ្របមុខខ្មោចមើល ក៏ចាំបានថាជាខ្មោចប្រុសសហាយខ្លួនប្រាកដ មេនោះក៏មានចិត្តអាណិតអាល័យដោយធ្លាប់បានរួមសង្វាសស្នេហានឹងគ្នាមក អត់ទឹកភ្នែកពុំបានក៏យំសោកអាល័យប្រុសសង្សារថា៖

ប្រុសអើយអ្នកប្រុស កាលអ្នកនៅរស់ ម្ដេចអ្នកមិនបួស ដល់មកក្ស័យ ទើបបានទ្រង់ផ្នួស លោកណាបំបួស អ្នកជាសាមណេរ ។

ឯលោកចៅអធិការបានឮភរិយានាយសំពៅយំរៀបរាប់ដូច្នោះ ក៏តក់ស្លុតព្រះទ័យគិតថាខណៈដែលអញបំបួសខ្មោចនាវេលារាត្រីនេះពុំមាននរណាមួយអាចឃើញអាចដឹងឡើយ នេះហេតុអ្វីក៏នាងភរិយានាយសំពៅមកយំរៀបរាប់ ត្រង់ឧបាយដែលអញធ្វើនេះ អេះ បើដូច្នេះខ្មោចនោះនឹងទុកយូរទៅពុំបាន ឃើញថានឹងកើតហេតុ គិតហើយលោកចៅអធិការនាំពួកឧបាសកឧបាសិកា ភិក្ខុសាមណេរចាត់ចែងលើកសពដាក់លើជើងថ្ករ ហើយអុចភ្លើងដុតខ្មោចនោះតាមបវេលាហោង ។

ឯមេភរិយានាយសំពៅមានក្ដីអាឡោះអាល័យអាប្រុសសហាយក៏យំភ្លាងអុជទៀនធូបសូមស្មាលាទោសនឹងសពនោះថា អ្នកចែកថានទៅហើយ កុំបីចងពៀរវេរាកម្មតទៅមុខឡើយ លុះដុតខ្មោចស្រេច



ហើយ ក៏លាលោកចៅអធិការវិលទៅកាន់គេហដ្ឋានៗ ប្ដីពុំហ៊ានតបតឲ្យក្រោធខឹង ព្រោះខ្លួនពុំបានដឹងក្នុងឧបាយមាយា គឺស្ដ្រីប្រព្រឹត្តដួដឹងខ្លួនជាខុស គិតកលឧបាយលលួងស្វាមី ឲ្យលង់វង្វេងកំហែងបានតាមចិត្តទៅផ្សេងៗហោង ។

**ចប់តម្រាមាយាស្ត្រីជាគតិទី ៦៩។**

ក្បួនគតិលោក មានរឿងយោងយោក ប្រៀបប្រាយតួយ៉ាង គតិបុរាណ ក៏មានបែបអាង លោកតែងម៉្យាងៗ តែពុំពិស្ដារ ។ ខ្ញុំទីឧកញ៉ា សុត្តន្តប្រីជា នាមឥន្ទាចារ្យ លើកឡើងលំដាប់ ជាច្បាប់វិត្ថារ តែដោយវោហារ ចងជាវគ្គៗ ។ សេចក្ដីស្ដាប់ងាយ សម្រាប់និយាយ យករូបរឿងដាក់ ប្រៀបធៀប មិនជិតដិត មានរាជការមកអង្កេតពិចារណារកខ្លួនអ្នកសម្លាប់នោះ គង់មិនមានក្ដីសង្ស័យ ។ ខ្ញុំយំសោកអាពារក្ដីយ៉ាងនេះ ខ្ញុំនឹងបានយំសោកអាល័យចោរដែលអ្នកសម្លាប់នោះក៏ឥតអង្គីមាន ។

---

ចប់